# កិច្ចការបញ្ចប់មេរៀនទី៣៧- យើងទៅមណ្ឌលសុខភាព

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ចម្រៀង: លំនាំបទផ្កាយលើមេឃ

| | | |
|---|---|---|
| គ្រូសូមផ្តែផ្តាំ | កូនត្រូវចងចាំ | ឱ្យបានច្បាស់ថា |
| ទាំងការរស់នៅ | ទាំងញ៉ាំអាហារ | ត្រូវចេះរក្សា |
| ធ្វើអនាម័យ | ត្រូវចេះរក្សា | ធ្វើអនាម័យ ។ (បន្ទរ) |
| កូនចៅប្រុសស្រី | ជំងឺសព្វថ្ងៃ | មានច្រើនកន្លង |
| តាមមកយាយី | ដល់មនុស្សសត្វផង | ដើម្បីចម្លង |
| រោគាដល់យើង | ដើម្បីចម្លង | រោគាដល់យើង ។ (បន្ទរ) |
| បើមានបញ្ហា | ចុកចាប់កាយា | ត្រូវរូតរះ |
| ទៅមណ្ឌលសុខភាព | ឱ្យបានរហ័ស | ជំងឺជាសះ |
| សុខភាពបវរ | ជំងឺជាសះ | សុខភាពបវរ ។ (បន្ទរ) |

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើពេលមានជំងឺកូនត្រូវរូតរះទៅព្យាបាលឯណា ?

☐ក. ផ្ទះអ្នកលក់ថ្នាំពេទ្យ ☐ខ. រោងអ្នកតាដើម្បីបន់ស្រន់

☐គ. នៅផ្ទះកោសខ្យល់ ☐ឃ. មណ្ឌលសុខភាព

២. តើក្នុងការរស់នៅ និងញ៉ាំអាហារ គ្រូបានផ្តែផ្តាំឱ្យកូនចងចាំអ្វីខ្លះ ?

☐ក. ញ៉ាំអាហារឱ្យបានច្រើន ☐ខ. កុំញ៉ាំរបស់ផ្អែមពេក

☐គ. ត្រូវចះរក្សា និងអនាម័យ ☐ឃ. ត្រូវធ្វើលំហាត់ប្រាណ

៣. ចូរសរសេរលេខ 1 2 ឬ 3 ក្នុងប្រអប់ដែលត្រូវនឹងអត្ថន័យនៃចម្រៀងខាងលើតាមលំដាប់លំដោយ

☐ ធ្វើអនាម័យ ត្រូវចេះរក្សា ធ្វើអនាម័យ

☐ គ្រូសូមផ្តែផ្តាំ កូនត្រូវចងចាំ ឱ្យបានច្បាស់ថា

☐ ទាំងការរស់នៅ ទាំងញ៉ាំអាហារ ត្រូវចេះរក្សា

៤. ចូររកបដិសព្ទនឹងពាក្យ " ឈឺ"

☐ក. អាក្រក់ ☐ខ. ល្អ ☐គ. ទុក្ខ ☐ឃ. ជា

LIVEWORKSHEETS

៥. ចូររកវេវចនសព្ទនឹងពាក្យ " ម្ដាយ " ឱ្យបានត្រឹមត្រូវ ។

- [ ] ក. មីង ម៉ាក់ ម៉ែ ញោមស្រី
- [ ] ខ. យាយ ម៉ាក់ ម៉ែ ញោមស្រី មាតា
- [ ] គ. ម៉ាក់ ម៉ែ ញោមស្រី មាតា
- [ ] ឃ. អ៊ំស្រី ម៉ាក់ ម៉ែ ញោមស្រី មាត

➢ សំណេរ

១. ចូរពន្យល់ពាក្យ "គ្រឿងទេស ភ្ញៀវ និទ្រា " ។

➢ ផ្កាំ ( ) ........................................................................................................

➢ អនាម័យ ( ) ....................................................................................................

➢ រោគា ( ) ........................................................................................................

២. ចូររៀបពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ឱ្យបានជាល្បះត្រឹមត្រូវ ។

ក.

| | | | | | |
|---|---|---|---|---|---|
| មណ្ឌលសុខភាព | នៅ | ម្ដាយខ្ញុំ | ទៅ | ជំងឺ | ពិនិត្យ |

.......................................................................................................

ខ.

| | | | | |
|---|---|---|---|---|
| ជំងឺកូវីដ១៩ | ជាមួយ | លាងដៃ | ការពារ | ខ្ញុំ |

.......................................................................................................

គ.

| | | | | | |
|---|---|---|---|---|---|
| មណ្ឌល | កូន | សុខភាព។ | ពូសាន | ទៅ | នាំ |

.......................................................................................................

៣. ចូរអានសំណួរខាងក្រោម រួចគូសភ្ជាប់ទៅសំណេរពាក្យឱ្យបានត្រឹមត្រូវ ។

| សំណួរពាក្យ | សំណេរពាក្យ |
|---|---|
| ១. រក័-សា | ក. សម្ងំ |
| ២. បញ្ហា-ហា | ខ. រហ័ស |
| ៣. រ-ហាស់ | គ. រក្សា |
| ៤. សំ-ងំ | ឃ. ក្រញាង |
| ៥. ក្រ-ញ៉ា | ង. បញ្ហា |

LIVEWORKSHEETS